ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

*****

**********

សំណុំរឿងព្រហ្មទណ្ឌ

លេខ:១៥

ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣

**សាលដីកា**

លេខ: ០៩

ចុះថ្ងៃទី២៦ខែមីនាឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ចៅក្រម

៥- លោក ស៊ិន ឃីម ចៅក្រម

**ក្រឡាបញ្ជី**

លោក សាន សុជាត

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

**<u>ពិរុទ្ធ:</u>** អំពើអនាចារ និងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរមនុស្សនិងធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

១-ជនជាប់ចោទឈ្មោះបាតធើរិត ក្លិនរិត (ហៅ)ក្លិហ្វ គុន (ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិអូស្រ្តាលី កើតនៅប្រទេសអូស្រ្តាលី របររកស៊ីគ្រូបង្រៀន ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ Bexelffon Better"រ" ម្ដាយឈ្មោះ Lda

grace Betterridge"រ" នៅលីវ ក្រៅឃុំ ។

-មានមេធាវី លោក ហែម វុន

២-ជនជាប់ចោទឈ្មោះ បាត ឡវ៉ើត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិបែលស៊ិច សញ្ជាតិអូស្រ្តាលី កើតនៅប្រទេសអូស្រ្តាលី របររកស៊ីគ្រូបង្រៀន ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុក សៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ Eyrif Lauwaert ម្ដាយឈ្មោះ Lau Ra Lauwaert នៅលីវ ។ ក្នុងឃុំ ។

-អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្ដឹងសាទុក្ខ)

១-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះហម ឡក់ ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅ សព្វថ្ងៃភូមិគោកដូង ក្រុម៦ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី អ្នកស្រី ស៊ិន ស៊ីវ៉ន

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះស៊ូ ឡា ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅ សព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោក លួង សុខា

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះនួន ណាត្រី ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើឆ្នប ទីលំនៅសព្វថ្ងៃភូមិគោកដូង ក្រុម៧ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី អ្នកស្រី ស៊ិន ស៊ីវ៉ន

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះប៊ុត រឿន ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅ សព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោកលី ប៊ុនចៀង

៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឡាយ ជឿន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មករ សំណង់ ទីលំនៅសព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោកលួង សុខា

៦-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះង៉ែ ជា ភេទស្រី អាយុ៧០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅ សព្វថ្ងៃភូមិសង្កែមានជ័យ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប ។

-មានមេធាវី លោកលួង សុខា

៧-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះតៀង ឡាំ ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោកលួង សុខា

១-ជនរងគ្រោះឈ្មោះឡាយ ស្រីម៉ុន ភេទស្រី អាយុ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

២-ជនរងគ្រោះឈ្មោះផាត់ ស្រីពៅ ហៅនាងកុមារី អាយុ១១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៣-ជនរងគ្រោះឈ្មោះគុន រ៉ាន់ ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៤-ជនរងគ្រោះឈ្មោះព្រេម លាវ កុមារី អាយុ១១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៥-ជនរងគ្រោះឈ្មោះតៀង លីកា កុមារី អាយុ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិសង្កែមានជ័យ ឃុំជីក្រែង ស្រុក-ខេត្តសៀមរាប ។

៦-ជនរងគ្រោះឈ្មោះនួន សុខុម ភេទស្រី អាយុ១៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៧-ជនរងគ្រោះឈ្មោះគឿន សាវី កុមារី អាយុ១៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៨-ជនរងគ្រោះឈ្មោះគឿន សាវ៉យ កុមារី អាយុ១២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៩-ជនរងគ្រោះឈ្មោះព្រេម ឡោម ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

១០-ជនរងគ្រោះឈ្មោះរុន រ៉ៃ ហៅស្រីពៅ ភេទស្រី អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

- តាមកំណត់ហេតុបណ្ដឹងចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះឡាយ ជឿន,ថ្ងៃទី៣០ ខែកក្កដាឆ្នាំ២០០២ របស់ឈ្មោះសោម ឡាំ,ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះនួន សុខុម,ឈ្មោះព្រេម ឡោម,ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះនុន រឿន,ប៊ិច រឿន,ហាម ឡក់ និងកំណត់ហេតុបណ្ដឹងចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះតេក នឿន ប្រធានអង្គការ **ewec** ថា: ខ្លួនបានទទួល

ដំណឹងពីក្មេងស្រីឈ្មោះជា លីកា ជាអ្នកបោសសំអាតបន្ទប់ឱ្យជនបរទេសឈ្មោះមិកិ ហើយត្រូវបានជនបរទេសរូបនោះប្រព្រឹត្តិអំពើអនាចារមកលើខ្លួន ។ ដូច្នេះសូមឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ និងបង់ជំងឺចិត្តចំនួន ៥០០០ដុល្លារ(ប្រាំពាន់ដុល្លារ) ។

-បានឃើញដីកាសំរេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ១១៧៣-០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ដែលបានសំរេច :

-មិនអនុញ្ញាតិឱ្យឈ្មោះបាត់ឡាវ៉ែត ដែលត្រូវចោទពីបទ:

១-អំពើអនាចារ និងរំលោភសេពសន្ទវៈប្រព្រឹត្តនៅភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ រហូតដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០២ ។

២-ប៉ុនប៉ងរំលោភសេពសន្ទវៈកាលពីខែកុម្ភៈ ឆ្នាំ២០០២ ប្រព្រឹត្តនៅភូមិថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

៣-សញ្ញាវិត ប្រព្រឹត្តនៅភូមិស្ទឹងថ្មី ភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងខែមេសា ឆ្នាំ២០០២ ហើយជនជាប់ចោទនេះមិនអនុញ្ញាតិឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នឡើយ ។

-មិនអនុញ្ញាតិឱ្យឈ្មោះបាត់ជើរិត ក្លិនវិត ដែលត្រូវចោទពីបទ:

១-អំពើអនាចារ និងរំលោភសេពសន្ទវៈប្រព្រឹត្តនៅ ភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ។

២-បើកកន្លែងប្រព្រឹត្តអំពើអនាចារ ឬអាសអាភាស និងសញ្ញាវិត ប្រព្រឹត្តនៅ ភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ។

៣-បៀតបៀនកេរ្តិ៍ខ្មាស់ប្រព្រឹត្តនៅភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងខែមេសា ឆ្នាំ២០០២ និងថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ។

៤-ប្រើប្រាស់ដោយខុសច្បាប់រុក្ខជាតិដែលចាត់ទុកជាថ្នាំញៀន ប្រព្រឹត្តជាអចិន្ត្រៃយ៍នៅភូមិត្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ហើយជនជាប់ចោទនេះមិនអនុញ្ញាតិឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នឡើយ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០២របស់ឈ្មោះឌី ប៊ូរីម៉ា មេធាវីការពារឱ្យជនជាប់ចោទ ប្តឹងមិនសុខចិត្តពីដីកាសំរេចលេខ១១៧៣-០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា: បដិសេធមិនអនុញ្ញាតិលើពាក្យបណ្តឹងសុំនៅក្រៅឃុំរបស់មេធាវីបានឡើយ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍

ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០២ របស់លោកមេធាវី ឌីបូរីម៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តម្កល់ដីកាសំរេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ១១៧៤/២០០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ឧត្តមានជ័យទុកជាបានការដដែល។

៣-បដិសេធដីកាសំរេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ១១៧/២០០២ ចុះថ្ងៃទី០៤ ខែមធ្នូ ឆ្នាំ២០០២របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ឧត្តមានជ័យ ចោលជាអសារបង់ ។

៤-អនុញ្ញាតិឱ្យឈ្មោះបាតធើរិត ក្លិនរិក (Betterridge eliont Rix) ហៅក្លិហ្វតុន ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិអូស្ត្រាលី របររកស៊ីគ្រូបង្រៀន ទីលំនៅមុនពេលចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលត្រូវចោទពីបទ :

ក-អំពើអនាចារ និងរំលោភសេពសន្ថវៈ កាលពីថ្ងៃទី ខែមេសា ឆ្នាំ២០០២ នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

ខ-បើកកន្លែងប្រព្រឹត្តអំពើអនាចារអាសអាភាស និងជាសញ្ចារិត កាលពីដើមខែមេសា ឆ្នាំ២០០២ នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

គ-បៀតបៀនកេរ្តិ៍ខ្មាសនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប គិតពីអំឡុងខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ ។

ឃ-ប្រើប្រាស់ដោយខុសច្បាប់នូវរុក្ខជាតិដែលចាត់ទុកជាថ្នាំញៀនប្រព្រឹត្តជាអចិន្ត្រៃយ៍នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប គិតពីក្នុងអំឡុងខែមេសា ឆ្នាំ២០០២ រហូតដល់ថ្ងៃ០៣ ខែសីហា ឆ្នាំ២០០២ ហើយជននេះត្រូវឃុំឃាំងខេត្តសៀមរាប តាមដីកាឃុំខ្លួនលេខ១៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ និងដីកាលេខ៣៤៦ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ឱ្យឈ្មោះនៅក្រៅឃុំជាបណ្តោះអាសន្នសិន ។

៥-បង្គាប់ឱ្យសមត្ថកិច្ចដោះលែងឈ្មោះបាតធើរិត ក្លិនរិក (Betterridge eliont Rix) ហៅក្លិហ្វតុន ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ប្រសិនបើឈ្មោះនេះពុំត្រូវឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

៦-សាលដីកានេះមានអនុភាពអនុវត្តភ្លាម១ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តសាលដីកាព្រហ្មទណ្ឌលេខ០១"ច"ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើចំណុចទី៣និងទី៥ នៃសេចក្ដីសំរេច ។

-បានឃើញសារណា ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញលិខិតបង្គាប់អោយធ្វើសារណា ឆ្លើយតបចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូលបង្គាប់អោយឈ្មោះបាត់ធើរិត ក្លីនរិត (ជាចុងបណ្ដឹងសាទុក្ខ) ធ្វើសារណាឆ្លើយតបពីសារណារបស់ឯកឧត្តមអគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍ ។ ហើយលោកឌី ប៊ូរីម៉ា មេធាវីរបស់ខ្លួនបានទទួលនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៣រួចហើយ ប៉ុន្តែពុំបានធ្វើសារណាតាមកំណត់ច្បាប់ទេ ដែលជាហេតុធ្វើអោយគ្មានសារណាឆ្លើយតបរបស់ចុងបណ្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : សាលាឧទ្ធរណ៍សំរេចឱ្យជនជាប់ចោទឈ្មោះបាតធើរិត ក្លិនរិត នៅក្រៅឃុំ ឃើញថាមិនត្រឹមត្រូវឡើយ ។

-ក្រឡាបញ្ជីអានសារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ នៅពេលជំនុំជំរះ ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះហម ឡក់ នៅពេលជំនុំជំរះ ថា : សុំឱ្យតុលាការដាក់ទោសលើជនជាប់ចោទមកដាក់គុកវិញ ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះស៊ូ ឡា នៅពេលជំនុំជំរះ ថា : បញ្ជូនជនជាប់ចោទមកដាក់គុកនៅស្រុកខ្មែរវិញ សំរេចតាមច្បាប់យល់ឃើញ ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះនួន ណាគ្រី នៅពេលជំនុំជំរះថា: នាងខ្ញុំមិនសុខចិត្តទេ សុខភាពកាន់តែទ្រុឌទ្រោមទៅៗដោយសារត្រូវថ្នាំញៀន ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះរុន រ៉ៃ នៅពេលជំនុំជំរះ ថា : សុំឱ្យតុលាការសំរេចទៅតាមច្បាប់ចុះ ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឡាយ ជឿន នៅពេលជំនុំជំរះ ថា : ខ្ញុំបាទមិនព្រម ប្អូនរបស់ខ្ញុំបាទធ្លាក់ខ្លួនឈឺ ខ្ញុំបាទគ្មានលុយមើលជំងឺទេ ។

-បានស្ដាប់ចម្លើយអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះតៀង ឡាំ នៅពេលជំនុំជំរះ ថា: សុំឱ្យតុលាការចាប់ជនជាប់ចោទឃុំវិញ ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោកហែម វុន មេធាវីការពារជនជាប់ចោទឈ្មោះបាតធើរិត ក្លីនរិត (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា : កូនក្ដីខ្ញុំមិនប្រើប្រាស់គ្រឿងញៀន ព្រោះនៅផ្ទះកើត

ហេតុគ្មានភស្តុតាងទេណាមួយការជួលផ្ទះនេះពុំមែនកូនក្តីខ្លួនបាទទេ។ ម្យ៉ាងទៀតជនរងគ្រោះទាំងអស់មកចូលធ្វើការក្នុងផ្ទះនេះមានការយល់ព្រមដែរ ដោយបានជួរការងារជាមួយប្រាក់ខែ ពុំមានការគាបសង្កត់ពីកូនក្តីខ្ញុំបាទឡើយ ។ ខ្ញុំមានភស្តុតាងដូចជា សំបុត្រពេទ្យបានបញ្ជាក់ថា ជនរងគ្រោះឈ្មោះគៀង លីកា ពុំបានបាត់បង់ភាពបរិសុទ្ធ និងឈ្មោះឡាយ ស្រីម៉ុន,គៀន សាវ៉យ និងគៀន សាវី ភាពបរិសុទ្ធបានបាត់បង់ទៅហើយ ។ ដូច្នោះកូនក្តីខ្ញុំគ្មានភស្តុតាងសំរាប់ដាក់បន្ទុកទេ សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះឃើញថាត្រឹមត្រូវសូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោកលី ប៊ុនថៀង មេធាវីការពារជនរងគ្រោះឈ្មោះរុន រ៉ែ នៅពេលជំនុំជំរះថា : តុលាការខេត្តសៀមរាបបានសំរេចដល់អង្គសេចក្តីដាក់ទោសជនជាប់ចោទ១០ឆ្នាំហើយ ដូច្នេះតុលាការកំពូលមិនអាចសំរេចផ្ទុយពីនេះបានទេ សូមតុលាការ បដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់អ្នកស្រីស៊ិន ស៊ីវ៉ន ជាមេធាវីការពារជនរងគ្រោះឈ្មោះព្រេម-ឡោម ,ព្រេម លាវ និង នួន សុខុម នៅពេលជំនុំជំរះថា : ការឱ្យជនជាប់ចោទនៅក្រៅឃុំនាំប៉ះពាល់ដល់នីតិវិធី អគ្គព្រះរាជអាជ្ញាប្តឹងសាទុក្ខហើយ សាលាឧទ្ធរណ៍នៅតែដោះលែងជនជាប់ចោទទៀត សូមតុលាការកំពូលសំរេចចាប់ខ្លួនជនជាប់ចោទមកដាក់គុកវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក លូង សុខា ជាមេធាវីការពារជនរងគ្រោះឈ្មោះឡាយ ស្រីម៉ុន,ផាត់ ស្រីពៅ,គុន រ៉ាន់,គៀង លីកា,គៀន សាវី និងឈ្មោះគៀន សាវ៉យ នៅពេលជំនុំជំរះថា : ការឱ្យជនជាប់ចោទនៅក្រៅឃុំ មិនត្រឹមត្រូវវាខុសនឹងច្បាប់ បាត់បង់ពីសំណងរដ្ឋប្បវេណីដែលត្រូវសងមកកូនក្តីខ្ញុំបាទ ។ ម្យ៉ាងតាមនីតិវិធី ការឱ្យជនជាប់ចោទនៅក្រៅឃុំត្រូវដាក់ប្រាក់ធានា ប៉ុន្តែក្នុងរឿងនេះពុំបានដាក់ប្រាក់ធានាទេ សូមតុលាការកំពូលសំរេចឃុំខ្លួនលើជនជាប់ចោទវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋច្រើន លើកច្រើនសារដែលច្បាប់ប្រទេសកម្ពុជាត្រូវហាមឃាត់ ។ ដូចច្នេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចឃុំខ្លួនជនជាប់ចោទវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ មេធាវីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា ឯកឧត្ដមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍បានប្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០១ "ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣និងទី៥ទេ ។ ដូច្នេះចំណុចក្រៅពីនេះ បានចូលជាស្ថាពររួចហើយ តុលាការកំពូលមានសមត្ថកិច្ចនៅពេលនេះជំនុំជំរះតែចំណុចទី៣ និងទី៥ នៃសាលដីកាខាងលើប៉ុណ្ណោះ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបដិសេធដីកាលេខ១១៧៤ / ២០០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ហើយសំរេចឱ្យជនជាប់ចោទឈ្មោះបាតធើរិត ក្លីនរិត ? (BATTERIDGE CLINT REX) ហៅក្លិហ្វតុន នៅក្រៅឃុំបណ្ដោះអាសន្នដោយអាងហេតុថា ពុំមានភស្ដុតាងដាក់បន្ទុកគ្រប់គ្រាន់ក្នុងបទឧក្រិដ្ឋ ដូចការចោទប្រកាន់ហើយអាចមានអំពើបៀតបៀនកេរ្ដិ៍ខ្មាស ដែលជាបទមជ្ឈឹមប៉ុណ្ណោះនោះគឺជាការខុសឆ្គងមួយដ៏ធ្ងន់ធ្ងរ ពីព្រោះសាលាឧទ្ធរណ៍បានរំលោភអំណាចនៅលើរឿងអង្គសេចក្ដីដែលស្ថិតនៅក្នុងសមត្ថកិច្ចតុលាការខេត្តសៀមរាបនៅឡើយ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះBATTERIDGE CLINT REX ត្រូវចោទពីបទល្មើសជាច្រើន រួមមានទាំងបទមជ្ឈឹមទាំងបទឧក្រិដ្ឋ គឺបទល្មើសដែលមានចែងនៅក្នុងមាត្រា៧ និង៨ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៣៣និង៤២នៃច្បាប់ព្រហ្មទណ្ឌអន្ដរកាល ព្រមទាំងមាត្រា៩៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្ដែចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប មិនទាន់បញ្ចប់ការស៊ើបអង្កេតផង បែរជាសាលាឧទ្ធរណ៍យល់ថា ពុំមានភស្ដុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទទៅវិញ ។

-យល់ឃើញថា ជនជាប់ចោទពុំមានទីលំនៅអចិន្ត្រៃយ៍ និងពិតប្រាកដលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទេ ហើយក៏ពុំមានទ្រព្យសម្បត្តិ ឬ ប្រាក់កាសសំរាប់ធានាសំណងដល់ជនរងគ្រោះដើម្បីសុំនៅក្រៅឃុំដែរ ជាក់ស្ដែងនៅពេលដែលសាលាឧទ្ធរណ៍សំរេចឱ្យជន នេះនៅក្រៅឃុំ ជននេះបានគេចខ្លួននិងពុំបានមកចូលរួមនាសវនាការនេះទេ។ដូច្នេះការដែលសាលាឧទ្ធរណ៍សំរេចឱ្យជនជាប់ចោទឈ្មោះBATTERIDGE CLINT REX នៅក្រៅឃុំបណ្ដោះអាសន្ន គឺជាការរំលោភលើលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្ដរកាល ព្រមទាំងពុំបានសំរេចឱ្យជនជាប់ចោទដាក់ប្រាក់ធានាដើម្បីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីមានការទុកចិត្តនៅពេលដែលតុលាការសំរេចសេចក្ដីជាស្ថាពរដែរ ។

-យល់ឃើញថា មេធាវីជនជាប់ចោទឈ្មោះបាតធើរិត ក្លីនរិត បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណា និងដីកាកោះឱ្យមកចូលរួមសវនាការនេះ តាមរយៈស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជាហើយ ប៉ុន្តែសាមីខ្លួនពុំបានធ្វើសារណា និងពុំបានមកចូលរួមនាសវនាការនេះទេ ហើយតុលាការកំពូលក៏បានចាត់តាំងមេធាវីម្នាក់ឱ្យការពារឱ្យជនជាប់ចោទនៅពេលសវនាការនេះដែរ ។ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីង៉ែ ជា ជាម្តាយជនរងគ្រោះឈ្មោះតឿង លីកា ពុំបានមកចូលរួមនាសវនាការនេះទេ ដោយមូលហេតុមានជំងឺ ប៉ុន្តែមេធាវីរបស់អ្នកស្រីបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខដែរ ។

-យល់ឃើញថា តុលាការកំពូលជំនុំជំរះនៅពេលនេះ តែលើបណ្តឹងសាទុក្ខរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ដែលមិនសុខចិត្តអំពីការសំរេចឱ្យជនជាប់ចោទឈ្មោះបាតធើរិត ក្លីនរិត នៅក្រៅឃុំ។ ដូច្នេះតុលាការកំពូលក៏ពុំមានសមត្ថកិច្ចពិចារណាដល់អង្គសេចក្តីថា ជនជាប់ចោទមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ឬពុំមានបានឡើយ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០១ "ច" ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីត្រង់ចំណុចទី៣ និងទី៥ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហាម ឡាក់,ស៊ូ ឡា ឆួន ណាត្រី,រុន ឡាញ់( កូនបិុត រឿន) ឡាយ ចឿន និងភឿង ឡាំ កំបាំងមុខជនជាប់ចោទ ឈ្មោះបាតធើរិត ក្លិនរិត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះង៉ែ ជា ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈចំណុចទី៣ និងទី៥ នៃសាលដីកាព្រហ្មទណ្ឌលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដោយឥតបង្វិល ។

៣-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះបាតធើរិត ក្លិនរិត ហៅក្លីហ្វតុន ( BATTERIDGE CLINT REX ( )CLIFTON) ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិអូស្ត្រាលី ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាន់លិខិតឆ្លងដែនលេខ L8770706យកទៅឃុំខ្លួននៅមន្ទីរឃុំឃាំងព្រៃសរ ជាបណ្តោះអាសន្ន រងចាំតុលាការសំរេចដល់អង្គសេចក្តីជាស្ថាពរ ។

**<u>ពីបទៈ</u>**

ក/ ប្រព្រឹត្តិអំពើអនាចារ និងរំលោភសេពសន្ថវៈ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០២ ប្រព្រឹត្តិនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

ខ/បើកកន្លែងប្រព្រឹត្តិអនាចារ និងជាសញ្ញារិត កាលពីដើមខែមេសា ឆ្នាំ២០០២នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ។

គ/ បៀតបៀនកេរ្តិ៍ខ្មាស នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ ។

ឃ / ប្រើប្រាស់រុក្ខជាតិដែលចាត់ទុកជាថ្នាំញៀនខុសច្បាប់ជាអចិន្ត្រៃយ៍ នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ។

បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៧និង៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស មាត្រា៣៣ និង៤២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលព្រមទាំងមាត្រា៩៨នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការខេត្តសៀមរាប ដើម្បីបញ្ចូលក្នុងអង្គសេចក្តី ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ ។